ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
**Ministry of Commerce**
No. ១០៧ MOC / SM 2008

# ប្រកាស

## ស្តីពី

## ការផ្តល់វិញ្ញាបនប័ត្រប្រភពដើមទំនិញតាមជើងយន្តហោះ បន្ទាប់ពីដឹកជញ្ជូនតាមរថយន្តឆ្លងកាត់ព្រំដែនកម្ពុជា

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ,
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែសីហា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- គោលបំណងបង្កលក្ខណៈងាយស្រួលដល់អ្នកនាំចេញកម្ពុជា ។

## សម្រេច

**ប្រការ ១ :** ក្រសួងពាណិជ្ជកម្មអនុញ្ញាតអោយអ្នកនាំចេញស្នើសុំវិញ្ញាបនប័ត្រប្រភពដើមទំនិញតាមជើងយន្តហោះ សំរាប់ទំនិញកម្ពុជាដែលដឹកជញ្ជូនតាមរថយន្តឆ្លងកាត់ព្រំដែនរួចហើយបន្តតាមជើងយន្តហោះទៅកាន់ទីផ្សារ ។

**ប្រការ ២ :** អ្នកនាំចេញដែលមកស្នើសុំវិញ្ញាបនប័ត្រជាមុនត្រូវមានទំនិញផលិតរួចយ៉ាងតិចបំផុត ៥០% នៃបរិមាណស្នើសុំសរុប ។

**ប្រការ ៣ :** ឯកសារចាំបាច់សំរាប់ដាក់ពាក្យស្នើសុំមាន :
- ពាក្យស្នើសុំ
- វិក័យប័ត្រ (Invoice)
- តារាងបញ្ជាក់ការវេចខ្ចប់ (Packing List)
- កិច្ចសន្យាទិញលក់
- មូលប្បទានប័ត្រសំរាប់សោហ៊ុយរដ្ឋបាល និងកំរៃគ្រប់គ្រងការនាំចេញ ។



ក្រសួងពាណិជ្ជកម្ម
២០ A & B មហាវិថីព្រះនរោត្តម
ភ្នំពេញ ១២២០៥
ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៤២៧ ៣៥៨ / ២១៤ ៩៤៦
ទូរសារលេខ: (៨៥៥) ២៣-២១៣-២៨៨ / ៩៩១-៧០៨
អ៊ីម៉ែល : moccabdir@yahoo.com

Downloaded from http://www.khmerlaws.com

**ប្រការ ៤ :** ក្នុងរយៈពេលយ៉ាងយូរបំផុត ៣០ ថ្ងៃ បន្ទាប់ពីទទួលបានវិញ្ញាបនប័ត្រប្រភពដើមរួចហើយ អ្នកនាំចេញត្រូវប្រគល់ជូនក្រសួងពាណិជ្ជកម្មនូវកំណត់ហេតុរួមរបស់គយ និងកាំកុងត្រូល និងអញ្ញត្តប័ណ្ណដឹកជញ្ជូនតាមជើងយន្តហោះ (Airway Bill) ។

**ប្រការ ៥ :** ក្នុងករណីមានការយឺតយ៉ាវក្នុងការផ្តល់ឯកសារដូចប្រការ ៤ ខាងលើ អ្នកនាំចេញត្រូវទទួលពិន័យលើកទី ១ នូវទឹកប្រាក់ ៤០.០០០.០០០ រៀល ។ ក្នុងករណីមិនរាងចាល លើកទី ២ ទឹកប្រាក់ពិន័យ ២០០.០០០.០០០ រៀល ។ ទឹកប្រាក់ពិន័យរៀងរាល់លើកនឹងត្រូវបង់ចូលថវិការដ្ឋ ។

**ប្រការ ៦ :** វិញ្ញាបនប័ត្រប្រភពដើមខាងលើត្រូវចំលងជូនសមត្ថកិច្ចគយ និង កាំកុងត្រូលនៅតាមមាត់ច្រកដើម្បីធ្វើការពិនិត្យផ្ទៀងផ្ទាត់ ។

**ប្រការ ៧ :** សមត្ថកិច្ចកាំកុងត្រូលនៅតាមមាត់ច្រកត្រូវផ្តល់កិច្ចសហប្រតិបត្តិការដោយផ្តល់ពត៌មានមកនាយកដ្ឋានដែល ផ្តល់វិញ្ញាបនប័ត្រប្រភពដើមពីការនាំចេញនេះ ដើម្បីសហការតាមដានបន្ត ។

**ប្រការ ៨ :** នាយិកាខុទ្ទកាល័យ អគ្គនាយកពាណិជ្ជកម្មអន្តរជាតិ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គាធិការ ប្រធាននាយកដ្ឋានកាំកុងត្រូល ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ប្រធាននាយកដ្ឋានពាណិជ្ជកម្មទ្វេភាគី ប្រធាននាយកដ្ឋានពាណិជកម្មពហុភាគី ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះអោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៨

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចម ប្រសិទ្ធ

**ចម្លងជូន :**

- ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាធិតីតេជោ ហ៊ុន សែន**
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង**
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ហោ ណាំហុង**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល
- ទីចាត់ការគយ និង រដ្ឋាករ
- ដូចក្នុងប្រការ ៨
- ឯកសារ-កាលប្បវត្តិ

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី១៧ ខែ៤ ឆ្នាំ២០០៨

ប្រធាននាយកដ្ឋានរដ្ឋបាល

ចន្ទ ចំនួនតារា



ក្រសួងពាណិជ្ជកម្ម
២០ A & B មហាវិថីព្រះនរោត្តម
ភ្នំពេញ ១២២០៥
ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨២៧ ៣៥៨ / ២១៥ ៩៨៦
ទូរសារលេខ: (៨៥៥) ២៣-២១៣-២៨៨ / ៩៩១-៧០៨
អ៊ីម៉ែល : moccabdir@yahoo.com

Downloaded from http://www.khmerlaws.com